**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

*ក្រសួងមហាផ្ទៃ*

**អគ្គលេខាធិការដ្ឋាន**

ការប្រញាប់

## កំណត់បង្ហាញលិខិតចូល

**ក្រសួង ខេត្ត ក្រុង ផ្ញើ** អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា **លេខ** ១៦៨/២៣ មពសក **ចុះថ្ងៃទី** ២៣.តុលា.២០២៣

**កម្មវត្ថុ:** សូមគោរពអញ្ជើញ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុក្រោមប្រធានបទ «ការទប់ស្កាត់អំពើជួញដូរស្ត្រីនិងក្មេងស្រី» នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១១:០០ ដល់ម៉ោង ១១:៥០នាទីព្រឹក នៅស្ថានីយវិទ្យុស្ត្រីអេហ្វអឹម ១០៣.៥។

**ខ្លឹមសារសង្ខេប:**

**សូមគោរពជូន លោកប្រធាននាយកដ្ឋាន**មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

-គួរគោរពជូន **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ និងស្នើជូន **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២៣

**ប្រធានការិយាល័យរបៀប**

វរសេនីយ៍ឯក.ចិន_សំ

### យោបល់អនុរដ្ឋលេខាធិការទទួលបន្ទុក

### យោបល់ ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី

24.10.23

សន្តិបណ្ឌិត.ម៉ៅ ច័ន្ទតារា

### យោបល់នាយកដ្ឋាន

**សូមគោរពជូន:ឯកឧត្តម អគ្គលេខាធិការ**

-**គួរគោរពជូន:** **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ និងស្នើជូន **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

24/10/23

ឧត្តមសេនីយ៍ត្រី ជាត់_ផល

### យោបល់ ឯកឧត្តមបណ្ឌិតសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### យោបល់អគ្គលេខាធិការរង

**សូមគោរពជូន:** **ឯកឧត្តម សន្តិបណ្ឌិត រដ្ឋមន្ត្រីស្តីទី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

-គួរជូន **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

24.10.23

ចាប់_វណ្ណៈ

CamScanner

# អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា
WOMEN'S MEDIA CENTRE OF CAMBODIA (WMC)

ពីទឹកចិត្តស្ត្រីដើម្បីសង្គម និងការអភិវឌ្ឍ
FROM WOMEN'S HEARTS FOR SOCIETY AND DEVELOPMENT

លេខ ១៦៨/២៣ មពសក

ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០២៣

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
លេខ 652
ថ្ងៃ 24.10.23 9h00
បញ្ជូន

**សូមគោរពជូន**

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ**: សូមគោរពអញ្ជើញ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុក្រោមប្រធានបទ «ការទប់ស្កាត់អំពើជួញដូរស្ត្រីនិងក្មេងស្រី»

យោងតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាជ្រាបថា វិទ្យុស្ត្រីនៃអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា នឹងរៀបចំផ្សាយផ្ទាល់កម្មវិធី "ភូមិសុខសាន្ត" ក្រោមប្រធានបទ «ការទប់ស្កាត់អំពើជួញដូរស្ត្រីនិងក្មេងស្រី» ក្នុងគោលបំណងផ្សព្វផ្សាយពីយន្តការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងក្មេងស្រី និងជំរុញឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងការជួយអន្តរាគមន៍ដល់ស្ត្រីនិងក្មេងស្រីដែលរងការជួញដូរទាំងក្នុងនិងក្រៅប្រទេសឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។ កម្មវិធីនេះមានការហៅទូរសព្ទចូលរួមពីប្រិយមិត្តអ្នកស្តាប់ និងមតិយោបល់ពីអ្នកទស្សនាលើបណ្តាញសង្គមផងដែរ។

| | | |
|---|---|---|
| កាលបរិច្ឆេទ | : | ថ្ងៃចន្ទ ទី៣០ ខែតុលា ឆ្នាំ២០២៣ |
| ពេលវេលា | : | ម៉ោង ១១ : ០០ ដល់ម៉ោង ១១ : ៥០នាទីព្រឹក |
| ទីកន្លែង | : | ស្ថានីយវិទ្យុស្ត្រីអេហ្វអឹម១០៣.៥ ផ្ទះលេខ២០ ផ្លូវ២៣D ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាអនុញ្ញាត **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អញ្ជើញចូលរួមជាវាគ្មិនក្នុងកម្មវិធីនេះដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

សូមភ្ជាប់ជូន
ខ្លឹមសារសំណួរទម្លាប់
ព័ត៌មានបន្ថែមសូមមេត្តាទាក់ទង
លោក នៀ សង្ហា ០១៥ ៧៥ ៩០ ០០

ជ.នាយិកាប្រតិបត្តិ

WOMEN'S MEDIA CENTRE OF CAMBODIA

ផាន់ ស័ក្ខបារមី

អាសយដ្ឋាន ផ្ទះលេខ ២០ ផ្លូវលេខ ២៣ដេ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
Address: No. 20, Street 23D, Phoumi Thmey, Sangkat Dangkor, Khan Dangkor, Phnom Penh, Cambodia,
Office Telephone: (855) 23 881 497, Marketing Telephone: (855) 12 202 102/ (855) 15 202 102
Email: info@wmc.org.kh, Website: www.wmc.org.kh, Women's Radio FM 103.5

CamScanner

# កម្មវិធី សំឡេងពលរដ្ឋ

ផលិតដោយ វិទ្យុស្ត្រីនៃអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា

(Call in show)

៚

ប្រធានបទទី១២: ការទប់ស្កាត់អំពើជួញដូរស្ត្រីនិងក្មេងស្រី

ផ្សាយផ្ទាល់ : ថ្ងៃចន្ទ ទី៣០ ខែតុលា ឆ្នាំ២០២៣

ម៉ោងផ្សាយ : ១១.០០ ដល់ ១១.៥០នាទីព្រឹក

វាគ្មិន/ភ្ញៀវ : លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

ធាតុផ្សំ : គ្មាន

គោលបំណង : ផ្សព្វផ្សាយពីយន្តការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងក្មេងស្រី និងជំរុញឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងការជួយអន្តរាគមន៍ដល់ស្ត្រីនិងក្មេងស្រីដែលរងការជួញដូរទាំងក្នុងនិងក្រៅប្រទេសឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

## សំណួរ

1. គិតត្រឹមឆ្នាំ ២០២៣នេះ តើមានការជួញដូរមនុស្សប៉ុន្មានករណី ក្នុងនោះមានស្ត្រីនិងកុមារីប៉ុន្មាននាក់?
2. តើរូបភាពនៃការជួញដូរមនុស្សបែបណាខ្លះដែលកំពុងកើតមាននៅកម្ពុជា ជាពិសេសការជួញដូរលើស្ត្រីនិងក្មេងស្រី?
3. តើអ្វីជាមូលហេតុចម្បងក្នុងការជួញដូរស្ត្រីនិងក្មេងស្រីបច្ចុប្បន្ន? តើឧក្រិដ្ឋជនភាគច្រើនជាមនុស្សក្រុមណា?
4. តើច្បាប់មានចែងដូចម្តេចទាក់ទងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងក្មេងស្រី? តើការជួញដូរទាំងនោះនិងទោសទណ្ឌដូចម្តេច?
5. តើអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងក្មេងស្រីនឹងបង្កផលប៉ះពាល់អ្វីខ្លះដល់សង្គមជាតិទាំងមូល?
6. តើភាគីពាក់ព័ន្ធណាខ្លះអាចចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងក្មេងស្រី?
7. សំណូមពរ/អនុសាសន៍

សូមទាក់ទងលោក នៀ សង្ហា

TELL: ០១៥ ៧៥ ៩០០០

TELEGRAM: ០៩៦ ៩៨ ៣៨ ១៩០

EMAIL: SONGHA.N@WMC.ORG.KH

CamScanner